June 5, 2019

# អង្គការសិទ្ធិមនុស្សស្នើឱ្យរដ្ឋាភិបាលកម្ពុជាបន្ទន់ឥរិយាបថចរចាជាមួយមន្ត្រីអឺរ៉ុបដែលចុះមកស្វែងរកការពិត



សហភាពអឺរ៉ុប @សហការី

**ដោយ វណ្ណ សុគន្ធា rfi 04/06/2019**

*គណៈប្រតិភូរបស់សហភាពអឺរ៉ុបបានមកដល់ប្រទេសកម្ពុជាហើយកាលពីថ្ងៃចន្ទម្សិលមិញនេះ ដើម្បីបន្តបេសកកម្មស្វែងរកការពិតពីស្ថានភាពសិទ្ធិមនុស្សដែលជាចំណែកមួយនៃដំណើរការនីតិវិធីព្យួរប្រព័ន្ធអនុគ្រោះពន្ធEBA។ តាមគម្រោងគណៈប្រតិភូនេះនឹងជួបជាមួយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងទៀត។ អង្គការការពារសិទ្ធិមនុស្សនៅកម្ពុជា បានស្នើឱ្យរដ្ឋាភិបាលខ្មែរបន្ទន់ឥរិយាបថពេលជួបចរចាជាមួយគណៈប្រតិភូអឺរ៉ុប ដើម្បីកុំឱ្យមានការព្យួរប្រព័ន្ធអនុគ្រោះពន្ធEBA។*

*លោកស៊ឹង សែនករុណា មន្ត្រីជាន់ខ្ពស់ផ្នែកស៊ើបអង្កេតនៃសមាគមការពារសិទ្ធិមនុស្សអាដហុក (ADHOC) បានលើកឡើងថា រដ្ឋាភិបាលកម្ពុជាគួរតែកែប្រែឥរិយាបថ ឬបន្ទន់ជំហរក្នុងជជែកចរចាជាមួយគណៈប្រតិភូ របស់សហភាពអឺរ៉ុបដែលបានចុះមកស្វែងរកការពិតជាថ្មីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។ សម្រាប់លោកស៊ឹង សែនករុណា ប្រសិនបើរដ្ឋាភិបាលកម្ពុជាបន្ទន់ជំហរធ្វើការចរចាជាមួយគណៈប្រតិភូអឺរ៉ុប នោះនឹងអាចស្វែងរកដំណោះស្រាយ ដើម្បីធ្វើយ៉ាងណាកុំឱ្យសហភាពអឺរ៉ុបឈានទៅសម្រេចដកប្រព័ន្ធអនុគ្រោះពន្ធEBAពីកម្ពុជា។*

ចំណែក លោកអំ សំអាត នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ (LICADHO)វិញ បានបង្ហាញក្តីរំពឹងថា នៅក្នុងជំនួបនាពេលខាងមុខនេះ រដ្ឋាភិបាលកម្ពុជា និងមន្ត្រីសហភាពអឺរ៉ុបនឹងជជែកគ្នា ដើម្បីឈានទៅរកការស្តារឡើងវិញនូវស្ថានភាពសិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។ បើតាមលោកអំ សំអាត តាំងពីការចុះមកស្វែងរកការពិតរបស់គណៈប្រតិភូអឺរ៉ុបកាលពីខែកក្កដា ឆ្នាំ២០១៨ មកដល់ពេលនេះ ស្ថានភាពសិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យនៅកម្ពុជានៅមិនទាន់មានភាពល្អប្រសើរនៅឡើយទេ។ ដូច្នេះហើយ លោកស្នើឱ្យរដ្ឋាភិបាលកម្ពុជាធ្វើការកែលម្អនូវបញ្ហាទាំងនេះឡើងវិញ ដើម្បីឱ្យសហភាពអឺរ៉ុបបន្តផ្តល់ប្រព័ន្ធអនុគ្រោះពន្ធEBA ដល់កម្ពុជា។

ឆ្លើយតបនឹងការលើកឡើងនេះ លោកផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជាបានអះអាងថា រដ្ឋាភិបាលមិនមានជំហរតឹងរ៉ឹងជាមួយសហភាពអឺរ៉ុបនោះទេ។ ប៉ុន្តែរដ្ឋាភិបាលកម្ពុជាប្រកាន់ជំហរតែមួយគត់ គឺការពារអធិបតេយ្យភាពរបស់ខ្លួន។ បើតាមលោកផៃ ស៊ីផាន រដ្ឋាភិបាលកម្ពុជាមិនអង្វរករសហភាពអឺរ៉ុបទេចំពោះបញ្ហាប្រព័ន្ធអនុគ្រោះពន្ធEBAនេះ ប៉ុន្តែនៅតែធ្វើការជាមួយគ្នាក្នុងនាមជាដៃគូ។

សូមបញ្ជាក់ថា គណៈប្រតិភូសហភាពអឺរ៉ុបបានមកដល់ប្រទេសកម្ពុជាកាលពីថ្ងៃចន្ទ ដើម្បីបន្តបេសកកម្មស្វែងរកការពិតពីស្ថានភាពសិទ្ធិមនុស្ស។ ការចុះមកស្វែងរកការពិតជាលើកទីពីរក្នុងសប្តាហ៍នេះ គណៈប្រតិភូសហភាពអឺរ៉ុបនឹងជួបជាមួយអង្គការការពារសិទ្ធិមនុស្សនៅថ្ងៃពុធ និង ព្រហស្បត្តិ៍ ដើម្បីប្រមូលព័ត៌មានពីការវិវត្តន៍ស្ថានភាពសិទ្ធិមនុស្សចុងក្រោយនៅកម្ពុជា។ ក្រៅពីនេះ គណៈប្រតិភូសហភាពអឺរ៉ុបក៏នឹងជួបជជែកជាមួយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជាផងដែរ។ ប៉ុន្តែការជួបជាមួយមន្ត្រីរូបណាខ្លះ និង នៅថ្ងៃណានោះ មិនត្រូវបានបង្ហាញឱ្យដឹងនោះទេ៕